UN-REDD
PROGRAMME

FAO UNDP UNEP

សេចក្តីប្រកាសព័ត៌មាន

**ការប្រកួតរូបថត**

កម្មវិធីជាតិ "កាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីការបាត់បង់ និងរេចរឹលព្រៃឈើកម្ពុជា" (រេដ+ ឬ REDD+) ដែលទទួលបានការគាំទ្រពីកម្មវិធី UN-REDD ដែលរួមមាន អង្គការកសិកម្មស្បៀងអាហារនៃសហ ប្រជាជាតិ(FAO), កម្មវិធីបរិស្ថានសហប្រជាជាតិ(UNEP) និង កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) មានកិត្តិយស សូមអញ្ជើញសាធារណជនដែលស្រលាញ់វិស័យថតរូប ចូលរួមការប្រកួតប្រជែងរូបថត ក្រោមប្រធានបទ **"ព្រៃឈើរបស់យើង ដើម្បីពិភពលោកបៃតង"**។

កម្មវិធីប្រកួតថតរូបនេះ រៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយ និងបង្កើនការយល់ដឹងអំពីទំនាក់ទំនងនៃបម្រែបម្រួលអាកាសធាតុនិងភាពក្រីក្រ តម្លៃនិងសារប្រយោជន៍ របស់ព្រៃឈើ កិច្ចការពារ គ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើឲ្យបានត្រឹមត្រូវ និងរួមចំណែកក្នុងការប្រយុទ្ធប្រឆាំងនឹងបម្រែបម្រួលអាកាសធាតុនៅលើពិភពលោក។

រូបថតដែលផ្ញើមកចូលរួមប្រកួត ត្រូវទាក់ទងនឹង ប្រធានបទ *ការការពារបរិស្ថាន ការការពារព្រៃឈើ ការការពារសហគមន៍ និងព្រៃឈើ*។

សាធារណជនដែលចាប់អារម្មណ៍និងចង់ចូលរួម សូមមើល **សេចក្តីជូនដំណឹង** និង**លក្ខខ័ណ្ឌនៃការចូលរួម** នៅក្នុងគេហទំព័រ http://www.cambodia-redd.org/category/document-centre/photo-contest។

ជ័យលាភីបីរូប និងជ័យលាភីលួងចិត្តចំនួន១៩រូប នឹងបានទទួលប័ណ្ណទំនិញពីក្រុមហ៊ុន Canon និងរង្វាន់បន្ទាប់បន្សំផ្សេងទៀត ហើយរូបថតទាំង២២នឹងត្រូវបានបោះពុម្ពនៅក្នុងឯកសារនានារបស់ REDD+។ ពិធីប្រគល់រង្វាន់ដល់ជ័យលាភីនឹងប្រព្រឹត្តទៅនៅក្នុងកម្មវិធីប្រគំតន្ត្រីសម័យ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង ៥:០០ ល្ងាច នៅមជ្ឈមណ្ឌលកោះពេជ្រ។

ដើម្បីចូលរួម បេក្ខជនអាចផ្ញើរូបថតទៅកាន់**អ៊ីម៉ែល** redd.secretariat@cambodia-redd.org ឬផ្ញើរទៅកាន់ **ការិយាល័យលេខាធិការដ្ឋានរេដ+** តាមអាស័យដ្ឋាន ផ្ទះលេខ៤០ មហាវិថីព្រះនរោត្តម ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ ដែលស្ថិតនៅក្នុងរដ្ឋបាលព្រៃឈើ ជាន់ទី៣។

-30-

**សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**


ទូរស័ព្ទលេខ៖ +៨៥៥ ២៣ ២២៤ ២៥១ ឬ +៨៥៥ ១២ ៥០០ ៩២២

អ៊ីម៉ែល៖ redd.secretariat@cambodia-redd.org

គេហទំព័រ៖ http://www.cambodia-redd.org/category/document-centre/photo-contest